**សុន្ទរកថា**

**ឯកឧត្តម ម៉ុង ចរិយា អគ្គនាយកប.ន**

**នាឱកាស សន្និសីទ សារព័ត៌មាន**

**ស្តីពី**

**លទ្ធផលនៃកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ ទូរគមនាគមន៍ និងព័ត៌មានវិទ្យា លើកទី១១**

(11th. TELSOM) **កាលពីថ្ងៃទី ១០-១២ មករា ឆ្នាំ២០១០**

**ទីក្រុង កូឡាឡាំពួរ , ម៉ាឡេស៊ី**

**សូមគោរព ឯកឧត្តមរដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់**

**ឯកឧត្តម រដ្ឋលេខាធិការ**

**ឯកឧត្តម លោកជំទាវអនុរដ្ឋលេខាធិការ ជាទីគោរព**

**លោក លោកស្រី ភ្ញៀវកិត្តិយស ជាទីរាប់អាន**

ឆ្នាំនេះជាឆ្នាំទី ១០នៃកិច្ចសហប្រតិបត្តិការរបស់អាស៊ាននៅក្នុងផ្នែកICT ។ ដើម្បីសំរេចនូវផែនការមេ Asean ICT Master Plan ២០១០-២០១៥ ក្នុងការបន្តដំណើរការទៅទៀត ដែលអាស្រយ័លើជ្រុងមួយដែល ឯកឧត្តម លោកជំទាវ អស់លោក បានមើលឃើញពីសមិទ្ធផលរបស់យើង ។

ជារួមមកយើងបានធ្វើការសំរេចចិត្តសំរាប់ពេលនេះថា ការចាប់ដៃគ្នាយ៉ាងណែនអាចនឹងគ្រប់គ្រាន់ ដើម្បីឱ្យដឹងអំពីកិរិតនៃការដែលយើងសំរេចបានសមិទ្ធផល នៅក្នុងរយៈពេល ១០ ឆ្នាំ កន្លងទៅនេះ ។ ជាមួយ នឹងមនុស្សជាង ៥០០លាននាក់ ហៅ អាស៊ាន ថាជាផ្ទះ ធ្វើឱ្យយើងពិតជាមិនអាចនៅសំងំស្ងៀមបានទេ ខណៈ ដែលប្រជាជាតិនៅក្នុងតំបន់ជាច្រើននៃអាស៊ាន នៅតែមិនទាន់ទទួលបានសេវា ICT ។

ទោះជាយ៉ាងណាក៏ដោយនេះក៏មិនមានន័យថាអាស៊ាននៅមិនទាន់មានការអភិវឌ្ឍន៍លើវិស័យICT នោះទេ។ ផ្ទុយទៅវិញ ប្រជាជនរបស់យើងលើសពី ៧៨ ភាគរយ កំពុងប្រើប្រាស់ ICT នៅក្នុងផ្នែក ផ្សេងៗ នៃជីវិតរបស់ពួកគេ។ សេវាអ៊ីនធឺណេតល្បឿនលឿន (ប្រដបែន Broadband) គឺជាការពិតមួយ នៅក្នុង អាស៊ាន ហើយការប្រើប្រាស់ និងសេវាកម្ម ICT ជាច្រើនទៀត ដែលមាននៅប្រទេសអភិវឌ្ឍន៍នានា ក៏កើតមាន ដូចគ្នានៅតាមបណ្តាប្រទេស អាស៊ានផងដែរ ។ យ៉ាងហោចណាស់ នៅក្នុងរដ្ឋសមាជិករបស់ អាស៊ានចំនួន ៥

ដែលជាប្រទេសដែលគ្របដណ្តប់ដោយ ទូរសព្ទ័ចលត័ បានឈានដល់ ១០០ភាគរយ ចំណែកឯករដ្ឋជាសមាជិក ផ្សេងទៀតក៏កំពុងតែមានទំនោរឆ្ពោះទៅកាន់ចំនុចនោះដែរ ។

**ឯកឧត្តមរដ្ឋមន្ត្រី**

**ឯកឧត្តម រដ្ឋលេខាធិការ**

**ឯកឧត្តម លោកជំទាវអនុរដ្ឋលេខាធិការ ជាទីគោរព**

**លោក លោកស្រី ភ្ញៀវកិត្តិយស ជាទីរាប់អាន**

ឧបករណ៍ឌីជីថល នឹងបន្តក្លាយជាកត្តាប្រគួតប្រជែងនៅអាស៊ាន។ ដោយសារថាធនធានរបស់យើងនៅមានកំណត់ អ្វីដែលសំខាន់នោះគឺការធ្វើសមាហរណកម្ម និងប្រើប្រាស់អោយមានប្រសិទ្ធភាពលើធនធានរបស់យើង ដើម្បីអនុវត្តវិធានការណ៍ថ្លៃដើមដ៏មានប្រសិទ្ធិភាព ដើម្បីឈានដល់អតិថិជនដ៏ទូលំទូលាយបំផុត នៅក្នុងកិច្ចខំប្រឹងប្រែងរបស់យើងដើម្បីផ្តល់នូវICTមួយដែលសមនឹងជីវភាពរបស់ប្រជាជន និងធ្វើឱ្យមានកំណើនដល់ការទទួលយករបស់ពួកគេ នៅពាសពេញអាស៊ាន។

ដោយសារយើងនឹងត្រូវធ្វើដំណើរឈានទៅឆ្នាំ ២០១៥ ជាពេលដែលអាស៊ាន នឹងក្លាយទៅជាសហគមន៍ទោលមួយ ដែលនឹងត្រូវធ្វើឡើងយ៉ាងសន្ធឹកសន្ធាប់លើការធ្វើសមាហរណកម្មប្រជាជន វប្បធម៌ និងសេដ្ឋកិច្ច បុគ្គល ដែលផ្នែកជាច្រើននៅក្នុងអាស៊ានត្រូវបានធ្វើឡើងរួចហើយនៅលើមូលដ្ឋានអនុវត្តជំហ៊ានដំបូងបំផុត ដើម្បីរៀបចំសំរាប់ឆ្នាំ២០១៥។ កិច្ចការទាំងនោះចាំបាច់ត្រូវធ្វើឡើងក្នុងលក្ខណៈរួបរួមដើម្បីគាំពារដល់ផ្នែកផ្សេងទៀតនៅក្នុងសេដ្ឋកិច្ច។ យើងមានភព្វ័វាសនាក្នុងការដែលមានធម្មនុញ្ញអាស៊ានដែលជាប្លង់មេ និងផែនទីផ្លូវ របស់សហគមន៍សេដ្ឋកិច្ចអាស៊ានសំរាប់សហគមន៍អាស៊ានមួយដើម្បីនាំផ្លូវពួកយើងក្នុងកិច្ចខំប្រឹងប្រែងមួយនេះ។

ជាលក្ខណៈសកល ICT ត្រូវបានទទួលស្គាល់ថាជាកត្តាគន្លឹះមួយនៅក្នុងការធ្វើកំណែទំរង់សង្គម និងសេដ្ឋកិច្ច។ អ្វីៗគឺស្ថិតនៅលើយើងដើម្បីធ្វើការរៀបចំប្លង់មេនេះឡើង សំរាប់អាស៊ាន ដើម្បីធ្វើការពង្រឹង (harness)ដល់សក្តានុពលរបស់ ICT នៅក្នុងការបង្កើតសហគមន៍សេដ្ឋកិច្ចរបស់អាស៊ាន។
មានការនិយាយជាច្រើនអំពីការ ទំនាក់ទំនងទៅវិញទៅមកយ៉ាងស្អិត រវាងអត្រាកំណើននៃការប្រើប្រាស់ប្រដបែន (Broadband) និងកំណើន GDP។ អាស៊ានត្រូវបានធ្វើការពិពណ៌នាជុំវិញរឿងនេះយ៉ាងច្រើន។ ក៏រិតខ្ពស់នៃការវិនិយោគពេលនេះត្រូវបានដាក់នៅខាងក្រោយ ការរៀបចំ ប្រដបែន (Broadband) និងហេដ្ឋារចនាសម្ពន្ធ័សំរាប់ជំនាន់ថ្មី (NGN) ដើម្បីផ្តល់សេវា ICT ដែលមានគុណភាពខ្ពស់ និងក្នុងតំលៃមួយសមរម្យ

ទៅដល់ប្រជាជនរបស់យើង និងភាគីដែលមានចំណាប់អារម្មណ៍នានា ដែលមានបំណងបង្កើតជាវត្តមានពាណិជ្ជកម្ម ឬ ជាលក្ខណៈឯកជននៅក្នុងតំបន់នេះ។

**ឯកឧត្តមរដ្ឋមន្ត្រី**

**ឯកឧត្តម រដ្ឋលេខាធិការ**

**ឯកឧត្តម លោកជំទាវអនុរដ្ឋលេខាធិការ ជាទីគោរព**

**លោក លោកស្រី ភ្ញៀវកិត្តិយស ជាទីរាប់អាន**

**ជាសរុប**

ដើម្បីទទួលស្គាល់ នូវទស្សនៈវិស័យនេះ វាចាំបាច់ណាស់ដែលត្រូវអនុវត្តលើផែនការមេ ឱ្យបានត្រឹមត្រូវតាមពេលវេលាកំណត់ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ពន្ធ័។ សំខាន់លើសពីនេះទៀត ធនធានត្រឹមត្រូវនានា ត្រូវតែត្រូវបានធ្វើការបែងចែក។ ផែនការមេនេះផ្តល់នូវឱកាសសំរាប់សហាកម្មសិទ្ធិថ្មី ដើម្បីរៀបចំ ICT ចាំបាច់ ដែលតំរូវដោយ អាស៊ាន ដើម្បីឈានទៅកាន់វេទិកាសហគមន៍សេដ្ឋកិច្ចដែលត្រូវបានធ្វើសមាហរណកម្មមួយ។

ដូច្នេះ អាស៊ានប្តេជ្ញា ធានាថា រាល់ឧបសគ្គដែលមាននៅក្នុងផែនការមេនេះ នឹងត្រូវបានរកឃើញក្នុងលក្ខណៈមួយយ៉ាងស្អិតរមួត។ ការធ្វើការវិនិយោគបន្ថែម លើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាន ICT នៅក្នុងតំបន់អាស៊ាន នឹងត្រូវបានតំរូវ។ យោងតាមនេះ អាស៊ាន ទទ្ទឹងរង់ចាំ ដើម្បីធ្វើការជាមួយគ្រប់ភាគីដែលមានចំណាប់អារម្មណ៍ដើម្បីសំរេចបានទស្សនៈវិសយ័របស់ផែនការមេ។

នៅពេលដែលផែនការមេអាស៊ាន ត្រូវបានអនុវត្តពេញលេញ ICT នឹងក្លាយទៅជាម៉ាស៊ីនមួយនៃការរីកចំរើនរបស់អាស៊ាន។ អាស៊ាននឹងក្លាយជា ICT Hub សកលមួយ ហើយគុណភាពនៃជីវិតរបស់ប្រជាជន នឹងត្រូវបានលើកកំពស់។ សំខាន់ជាងនេះទៅទៀត វានឹងត្រួសត្រាយផ្លូវសំរាប់ការធ្វើសមាហរណកម្មអាស៊ានទៅជាសហគមន៍តែមួយ។

ជាបញ្ចប់ ខ្ញុំសូមគោរពជូនពរឯកឧត្តម រដ្ឋមន្ត្រី ឯកឧត្តម រដ្ឋលេខាធិការ ឯកឧត្តម លោកជំទាវអនុរដ្ឋលេខាធិការ លោក លោកស្រី ប្រកបដោយសុខភាពល្អ កម្លាំងពលំមាំមួន និងសំរេចបានជោគជ័យត្រចះត្រចង់ក្នុងគ្រប់ភារកិច្ច ដើម្បីបុព្វហេតុជាតិ មាតិភូមិ និងការអភិវឌ្ឍ។

**អរគុណ !!!**